ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ សុក្រ ០៩ រោច ខែ មិគសិរ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលនៃកិច្ចប្រជុំត្រួតពិនិត្យការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រចំនួន ៤ និងការរៀបចំផែនការសកម្មភាពសម្រាប់ការកាត់បន្ថយនីតិវិធី និងការគ្រប់គ្រងការផ្លាស់ប្តូរក្នុងការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាព្រឹកទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានដឹកនាំកិច្ចប្រជុំពិភាក្សាអំពីការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រចំនួន ៤ និងការរៀបចំផែនការសកម្មភាពក្នុងការកាត់បន្ថយនីតិវិធី និងការគ្រប់គ្រងការផ្លាស់ប្តូរនៅពេលដាក់ឲ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System - FMIS) ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំ និងសមាជិកក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការរៀបចំផែនការសកម្មភាពអនុវត្តន៍ទាំងនេះ គឺជាកិច្ចការប្រតិបត្តិសម្រាប់គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ដើម្បីធានាឲ្យបាននូវភាពគ្រប់ជ្រុងជ្រោយ, សង្គតិភាព, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, ការទទួលខុសត្រូវ និងអាចសម្រេចបានតាមគោលដៅដែលបានកំណត់ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការៀបចំសេចក្តីព្រាងផែនការសកម្មភាពអនុវត្តន៍ រួមមាន÷

### *ទី ១. ផែនការសកម្មភាពសម្រាប់យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣÷*

ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ត្រូវបែងចែកជា ២ ផ្នែក÷ ១. ទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលសារពើពន្ធ និងការពង្រឹងរដ្ឋបាលសារពើពន្ធ និង ២. គោលនយោបាយចំណូលមិនមែនសារពើពន្ធ ។ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តយុទ្ធសាស្ត្រយុទ្ធសាស្ត្រកៀរគរចំណូលនេះ ក៏ដូចជា ដើម្បីជំរុញឱ្យសម្រេចបាននូវគោលបំណងនៃការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដែលធានាបាននូវចីរភាពកំណើនចំណូល, សកម្មភាពអនុវត្តន៍សរុបមានចំនួន ៣៧១ ត្រូវបានរៀបចំ ។ សកម្មភាពទាំងនោះបានគូសបញ្ជាក់ច្បាស់លាស់នូវអង្គភាពទទួលខុសត្រូវ, ក្របខ័ណ្ឌ ពេលវេលាអនុវត្តន៍តាមត្រីមាសនៃឆ្នាំនីមួយៗ ដើម្បីធានាឱ្យសម្រេចបានតាមវិធានការ និងសូចនាករសមិទ្ធកម្មគន្លឹះដែលបានកំណត់ឡើង ។

### *ទី២. ផែនការសកម្មភាពសម្រាប់យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥÷*

ផែនការសកម្មភាពសម្រាប់អនុវត្តន៍យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥ ត្រូវបានរៀបចំផ្អែកលើផែនទីចង្អុលផ្លូវ និងស្របតាមវិធានការដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥ ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា នាថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៩ កន្លងមក ។ សកម្មភាពដែលជាសមាសធាតុគន្លឹះៗ ចំនួន ១៩ ដែលចែកចេញជាសកម្មភាពលម្អិតចំនួន ៩៥ សម្រាប់ដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ ២០១៩ រហូតដល់ឆ្នាំ ២០២៥ ត្រូវបានរៀបចំឡើង ។

***ទី៣. ផែនការសកម្មភាពសម្រាប់យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥÷***

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ ត្រូវបានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា នាថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៩ កន្លងមក ហើយផែនការសកម្មភាពសម្រាប់អនុវត្តន៍យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងក្នុងគោលដៅឆ្ពោះទៅការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកា សម្រាប់ឈានទៅអនុវត្តប្រព័ន្ធ ***«ថវិកាព័ត៌មានសមិទ្ធកម្ម»*** ក្រោយឆ្នាំ ២០២៥ ។ សកម្មភាពអនុវត្តន៍សរុបចំនួន ១៤១ ចែកជា ០៦ ផ្នែក, ១៣ គោលបំណង និង ០២ ដំណាក់កាល ត្រូវបានរៀបចំឡើងដើម្បីសម្រេចបានតាមបង្គោលចរនៃផែនទីចង្អុលផ្លូវ និងវដ្តថវិកា ។

***ទី៤. ផែនការសកម្មភាពយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ២០១៩-២០២៥÷***

យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៩ កន្លងមក និងប្រកាសដាក់ឱ្យអនុវត្តនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៩ កន្លងមក ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈត្រូវបានរៀបចំស្របតាមវិធានការដែលបានដាក់ចេញ ក្នុងនោះមាន វិធានការ និងផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ ។

***ទី៥. ផែនការសកម្មភាពស្តីពីការកាត់បន្ថយនីតិវិធី និងការគ្រប់គ្រងការផ្លាស់ប្តូរសម្រាប់អនុវត្ត FMIS÷***

ផែនការសកម្មភាពស្តីពីការកាត់បន្ថយនីតិវិធី និងការគ្រប់គ្រងការផ្លាស់ប្តូរសម្រាប់អនុវត្ត FMIS ត្រូវបានរៀបចំឡើង ដើម្បីតម្រង់ទិសនីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្សារភ្ជាប់ជាមួយនឹងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (Financial Management Information System - FMIS) (២០១៩-២០២៥) ក្នុងនោះផែនការសកម្មភាពបានគ្របដណ្តប់លើ÷

- នីតិវិធីអនុវត្តការងារដែលផ្សារភ្ជាប់ការប្រើប្រាស់ប្រព័ន្ធ FMIS នៅគ្រប់ការដ្ឋាន ដោយផ្អែកលើអភិក្រមជាជំហានៗ "ហានិភ័យ និងវេទយិតភាពពីទាបទៅខ្ពស់" និងផ្តើមចេញពីនីតិវិធីអនុវត្តការងារនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តថវិកាចរន្ត ដោយដាក់អនុវត្តនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមុនគេ ដើម្បីផ្តល់ជាគំរូ និងបន្តអនុវត្តនៅក្រសួង-ស្ថាប័ន និងអង្គភាពនានា ទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់មូលដ្ឋាន ដែលប្រើប្រាស់ប្រព័ន្ធ FMIS ។
- នីតិវិធីអនុវត្តការងារលើ÷ ១. ការធានាចំណាយ និងទូទាត់ចំណាយ, ២. ការធ្វើចលនាឥណទានថវិកា, ៣. ការអនុវត្តចំណូលថវិកា និង ៤ . នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម ។

បន្ទាប់ពីកិច្ចប្រជុំពិភាក្សាលើផែនការសកម្មភាពលម្អិតនីមួយៗ, កិច្ចប្រជុំ ក៏បានឯកភាពជាគោលការណ៍លើការរៀបចំផែនការសកម្មភាពទាំងនេះ និងស្នើគ្រប់អង្គភាពទទួលបន្ទុក ត្រូវពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាដៃគូអភិវឌ្ឍន៍បន្ថែមទៀត ។